**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១២៦៨ សហវ-ទស

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១១

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**

**កម្មវត្ថុ:** សំណើសុំគោលការណ៍ចំណាយថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» ជូននាយកដ្ឋានធារាសាស្ត្រ នៃក្រសួងធនធានទឹក និងឧតុនិយម ចំនួន ៦ ៧៦៥ ៩៨០ ៧៦៩ រៀល សម្រាប់ការងារជួសជុលទំនប់និងសាងសង់សំណង់សិល្បការ លើទំនប់អាងទឹក ២០ឧសភា ស្រុកបរិបូណ៌ និងស្រុកលាបៀរ ខេត្តកំពង់ឆ្នាំង ។

**យោង:** - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- លិខិតលេខ ០៨០ ធទឧ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹកនិងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមផ្តល់ជានាចំណាយជូនចំនួន ៦ ៦៥៣ ០០០ ០០០ រៀល(ប្រាំមួយពាន់ប្រាំមួយរយហាសិបបីលានរៀលគត់) ដោយប្រើប្រាស់ឥណទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» សម្រាប់ឲ្យនាយកដ្ឋានធារាសាស្ត្រនៃក្រសួងធនធានទឹកនិងឧតុនិយម អនុវត្តការងារជួសជុលទំនប់និងសាងសង់សំណង់សិល្បការ លើទំនប់អាងទឹក ២០ឧសភា ស្រុកបរិបូណ៌ និងស្រុកលាបៀរ ខេត្តកំពង់ឆ្នាំង រួមមាន៖

| | |
|---|---|
| -ជួសជុលទំនប់ និងដាំស្មៅតាមជើងទេរទំនប់ | ប្រវែង ៤.០៥០ម |
| -ក្រាលក្រួសក្រហមលើខ្នងទំនប់ | ប្រវែង ៤.០៥០ម |
| -សាងសង់សំណង់ទ្វារទឹក លើទំនប់(ទ្វារ ១៥) | ចំនួន ០១កន្លែង |
| -ជួសជុលសំណង់ទ្វារទឹកលើទំនប់ | ចំនួន ០១កន្លែង |
| -រៀបថ្មធំស្លុតការពាររលកជើងទេរទំនប់ សងខាង | ប្រវែង ៨៥០ម |
| -សាងសង់សំណង់លូជ្រុងលើទំនប់ | ចំនួន ០៥កន្លែង |

សេចក្តីដូចបានជម្រាបខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- សាលាខេត្តកំពង់ឆ្នាំង
- នាយកដ្ឋានធារាសាស្ត្រនៃក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីមុខការ»
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com